**សហគមន៍ខ្មែរកម្ពុជាក្រោម**

**KHMER KAMPUCHEA KROM COMMUNITY**

**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ..................................ស.ខ.ក.ក.

# សេចក្ដីអំពាវនាវ

ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ ជាខួបគម្រប់ ៦៤ឆ្នាំ (០៤.០៦.ព.ស.២៤៩៣ គ.ស.១៩៤៩ - ០៤.០៦.ព.ស.២៥៥៧ គ.ស.២០១៣) នៃថ្ងៃអាណានិគមបារាំងបានកាត់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យអាណានិគមវៀតណាមត្រួតត្រាបន្តរហូតសព្វថ្ងៃ។ ក្រោមការត្រួតត្រារបស់អាណានិគមវៀតណាមក្នុងរយៈពេល៦៤ឆ្នាំកន្លងមកនេះ ព្រះសង្ឃនិងប្រជារាស្ត្រខ្មែរកម្ពុជាក្រោម បានរស់នៅក្រោមនឹមដែកអម្រែកធ្ងន់យ៉ាងមហាវេទនាជាទីបំផុត។ មិនតែប៉ុណ្ណោះត្រូវបានអាជ្ញាធរអាណានិគមវៀតណាមចាត់ទុកថា ជាជនជាតិភាគតិចនៅលើទឹកដីកំណើតរបស់ខ្លួនទៀតផង។

ភាពគង់វង្សពូជសាសន៍ សាសនា ទំនៀមទម្លាប់ វប្បធម៌ អក្សរសាស្ត្រនិងប្រពៃណីដ៏ល្អផូរផង់របស់ខ្មែរនៅលើទឹកដីកម្ពុជាក្រោមសព្វថ្ងៃ មិនមែនដោយសារមេត្តារបស់អាណានិគមវៀតណាមនោះឡើយ ទោះបីស្ថិតនៅក្នុងសម័យកាលណាក៏ដោយ គឺដោយសារព្រះសង្ឃ និងប្រជារាស្ត្រខ្មែរនៅទីនោះ បានតស៊ូយ៉ាងប្ដូរផ្ដាច់ ដោយមិនរួញរាក្នុងការពលីជីវិតរាប់មិនអស់ ។

ដើម្បីសម្ដែងនូវកតញ្ញូតាធម៌ និងគារវកិច្ច ចំពោះព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ វិញ្ញាណក្ខន្ធវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារី ខ្មែរស្នេហាជាតិទាំងអស់ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម បានរៀបចំធ្វើពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន១៩៤៩អង្គ និងប្រារព្ធទិវាកាន់ទុក្ខជាតិខ្មែរ៤មិថុនា ថ្ងៃអាណានិគមបារាំងបានកាត់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យវៀណាមជារៀងរាល់ឆ្នាំ ដើម្បីឲ្យប្រជារាស្ត្រខ្មែរគ្រប់រូបចងចាំនូវថ្ងៃប្រវត្តិសាស្ត្រដ៏សែនឈឺចាប់នេះ ប្រយោជន៍ជៀសវៀងកុំឲ្យជានប្រវត្តិសាស្ត្រចាស់វិលមកសារជាថ្មីទៀត។

ដើម្បីមានលទ្ធភាពរៀបចំពិធីបុណ្យដូចបានទូលប្រគេននិងជម្រាបជូនខាងលើ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម សូមអំពាវនាវដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនរួមឈាម ជាពិសេស បងប្អូនរួមឈាមខ្មែរនៅឯនាយសមុទ្រ ព្រះមេត្តានិងមេត្តាជួយឧបត្ថម្ភ ដូចជាចង្ហាន់ព្រះសង្ឃ ទឹកបរិសុទ្ធ ឬជាថវិកា ដើម្បីខ្ញុំព្រះករុណាទាំងឡាយយើងខ្ញុំ មានលទ្ធភាពរៀបចំពិធីបុណ្យឲ្យបានជោគជ័យ តាមការគួរ។

សេចក្ដីអំពាវនាវនេះ ទុកជាសេចក្ដីគោរពនិមន្ត និងអញ្ជើញ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនរួមឈាមខ្មែរទាំងអស់ ព្រះមេត្តានិងមេត្តានិមន្តនិងអញ្ជើញចូលរួមឲ្យបានច្រើនកុះករ ដើម្បីញ៉ាំងកម្មវិធីបុណ្យជាប្រវត្តិសាស្ត្រនេះ ឲ្យមានសភាពឱឡារិកអធិកអធម និងប្រកបដោយជោគជ័យ ព្រមទាំងចាប់យកមគ្គផលកុសលបុណ្យរៀងៗអង្គនិងខ្លួនកុំបីអាក់ខានឡើយ។

កម្មវិធីបុណ្យនឹងប្រព្រឹត្តទៅក្រោមព្រះអធិបតីភាពព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃ**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅសួនច្បារខាងមុខវត្តបទុមវតី រាជធានីភ្នំពេញ នាថ្ងៃអង្គារ ១១រោច ខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៥៥៧ ត្រូវនឹងថ្ងៃទី០៤ ខែមិថុនា គ.ស.២០១៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹក រហូតដល់ម៉ោង១១:00ថ្ងៃត្រង់ និងមានរាប់បាត្រព្រះសង្ឃចំនួន១៩៤៩អង្គ ជាកិច្ចបង្ហើយបុណ្យ។ សូមអរព្រះគុណ និងអរគុណ !

ភ្នំពេញ, ថ្ងៃចន្ទ ១២កើត ខែចេត្រ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៥៥៦
ត្រូវនឹងថ្ងៃទី២២ ខែមេសា គ.ស.២០១៣

ប្រធានគណៈកម្មការបុណ្យ

**ថាច់ សេដ្ឋា**

សមាជិកព្រឹទ្ធសភា
នាយកប្រតិបត្តិសហាគមន៍ខ្មែរកម្ពុជាក្រោម

*សម្រាប់ព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន គង់និងរស់នៅសហរដ្ឋអាមេរិក ប្រទេសកាណាដា ព្រមទាំងនៅបណ្តាប្រទេសនានា សូមផ្ញើសែករូបិយវត្ថុទៅលោក ថាច់ រ៉ា តាមអាសយដ្ឋាននៅខាងក្រោម ÷*

For U.S., Canada residents and other countries, please kindly make payable personal check, traveler's check or money order and send it to:

**RA THACH**
P.O. BOX 37502
PHILADELPHIA, PA 19148
U.S.A.

---------------------------------------------------

*សម្រាប់ព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន គង់និងរស់នៅព្រះរាជាណាចក្រកម្ពុជា និងនៅលើទឹកដីកម្ពុជាក្រោម សូមនិមន្តនិងអញ្ជើញទាក់ទងទៅអាសយដ្ឋានខាងក្រោម ÷*

For residents of Cambodia and Kampuchea Krom, please kindly contact us at an address below:

The Khmer Kampuchea Krom Community, KKC
House No. 10B, Street 234, Tuk Laak 3 commune, Tuol Kork district
Phnom Penh, Kingdom of Cambodia
Phones: 011.855.12.908.882, 011.855.090.477.007

---------------------------------------------------

*សម្រាប់ព័ត៌មានទូទៅ សូមព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន និមន្តនិងអញ្ជើញទាក់ទងទៅតំណាងសហគមន៍តាមរយៈលេខទូរស័ព្ទនិងអាសយដ្ឋានអ៊ីមែលដូចមាននៅខាងក្រោម÷*

General Contact Info:

| | | |
|---|---|---|
| គិម វុឌ្ឍី | Vithi Kim | 864.494.1991 |
| សឺន ស៊ីណា | Sina Son | 267.242.3608 |
| គិម សារេត | Saret Kim | 978.328.4435 |

For inquiries, please email us at this address: KKCpressoffice@yahoo.com.

សូមអរព្រះគុណ និងសូមអរគុណ។ Thank you for your charity.